00711570

D364/1/6


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire


*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ៤៧ និង អបជ៥៣)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ណ័យ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១១

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 07 / 2011
ម៉ោង (Time/Heure): 14:06
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**សាធារណៈ**

# សាលដីកាសម្រេចអំពីការពិចារណាសារជាថ្មីឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន
នួន ជា

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

**សហមេធាវីការពារជនត្រូវចោទ**
អាង ឧត្តម

00711571

សំ សុគង់
Lyma Thuy NGUYEN
ហុង គឹមសួន
Pascal AUBOIN
ពេជ អង្គ
ជេត វណ្ណលី
វ៉ែន ពៅ
ឡោ ជុនធី
Olivier BAHOUGNE
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Christine MARTINEAU
Elizabeth RABESANRATANA
Philippe CANONNE
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
គង់ ពិសី
យុង ផានិត
ស៊ិន សុវ៉ន
Silke STUDZINSKY
Mahdev MOHAN
Patrick BAUDOIN
Marie GUIRAUD
ទី ស្រីនណា
Ferdinand DJAMMEN-NZEPA
Isabelle DURAND
Emmanuel ALTIT
Emmanuel JACOMY
Barnabe NEKUIE
Daniel LOSQ
Julien RIVET
Francoise GAUTRY
Laure DESFORGES

Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
សុន អារុណ
Michiel PESTMAN
Victor KOPPE
ស សុវ៉ាន
Jacques VERGES

E.C.C.C * C.E.T.C
CHAMBRE PRELIMINAIRE

**អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ("អ.វ.ត.ក") បានទទួលបណ្តឹងឧទ្ធរណ៍ទាំងឡាយ[1]ដែលបានដាក់ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាផ្សេងៗរបស់សហចៅក្រមស៊ើបអង្កេត សម្រេចអំពីការទទួលយកពាក្យសុំនានាដែលបានដាក់ដោយជនរងគ្រោះដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីនៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ដែលអង្គបុរេជំនុំជម្រះបានចេញសាលដីកា នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១[2]។ នៅក្នុងដំណើរការពិចារណាលើបណ្តឹងឧទ្ធរណ៍ទាំងអស់នេះ មតិភាគច្រើននៃអង្គបុរេជំនុំជម្រះ (មតិភាគច្រើន) បានកត់សម្គាល់ឃើញថា ខុសពីដើមបណ្តឹងរដ្ឋប្បវេណីជនជាតិវៀតណាមទាំង១៥នាក់ ដែលបានដាក់សំណើសុំពិចារណាសារជាថ្មីឡើងវិញជាមួយបណ្តឹងឧទ្ធរណ៍ អបជ ៧៤ ភាគីមួយចំនួនដែលបានប្តឹងឧទ្ធរណ៍កាលពីពេលមុនទៅអង្គបុរេជំនុំជម្រះដោយឡែកពីគ្នានៅក្នុងបណ្តឹងឧទ្ធរណ៍ អបជ ៤៧ និង អបជ ៥៣ និងត្រូវបានបដិសេធនោះ មិនបានដាក់សំណើសុំឱ្យពិចារណាសារជាថ្មីឡើងវិញ[3] អំពីសាលដីកាលើបណ្តឹងឧទ្ធរណ៍ទាំងនេះនោះទេ។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ដោយកត់សម្គាល់ឃើញថា "សាលដីកាកាលពីពេលមុនលើបណ្តឹងឧទ្ធរណ៍ អបជ ៤៧ និងអបជ ៥៣ ដែលត្រូវបានដាក់ប្រឆាំងនឹងដីកានានារបស់សហចៅក្រមស៊ើបអង្កេត សម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានប្រសិទ្ធភាពបដិសេធ [អ្នកដាក់ពាក្យសុំមួយចំនួន] ដោយផ្អែកលើមូលដ្ឋានច្បាប់

[1] អបជ ៧៣, អបជ ៧៤, អបជ ៧៦, អបជ ១១២, អបជ ១១៣, អបជ ១១៤, អបជ ១១៥, អបជ ១១៦, អបជ ១១៧, អបជ ១១៨, អបជ ១១៩, អបជ ១២០, អបជ ១២១, អបជ ១២២, អបជ ១២៣, អបជ ១២៤, អបជ ១២៥, អបជ ១២៦, អបជ ១២៧, អបជ ១២៨, អបជ ១២៩, អបជ ១៣០, អបជ ១៣១, អបជ ១៣២, អបជ ១៣៣, អបជ ១៣៤, អបជ ១៣៥, អបជ ១៣៦, អបជ ១៣៧, អបជ ១៣៨, អបជ ១៣៩, អបជ ១៤០, អបជ ១៤១, អបជ ១៤២, អបជ ១៤៣, អបជ ១៤៤, អបជ ១៤៨, អបជ ១៤៩, អបជ ១៥០, អបជ ១៥១, អបជ ១៥៣, អបជ ១៥៤, អបជ ១៥៥, អបជ ១៥៦, អបជ ១៥៧, អបជ ១៥៨, អបជ ១៥៩, អបជ ១៦០, អបជ ១៦១, អបជ ១៦២, អបជ ១៦៣, អបជ ១៦៤, អបជ ១៦៥, អបជ ១៦៦, អបជ ១៦៧, អបជ ១៦៨, អបជ ១៦៩, អបជ ១៧០, អបជ ១៧១, និង អបជ ១៧២។

[2] សូមមើល សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D404/2/4 និង D411/3/6។

[3] សូមមើល សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ១១៧។

ដោយភ័ន្តច្រឡំ" មតិភាគច្រើនបានសម្រេចថា ខ្លួនត្រូវធ្វើការពិចារណាលើបញ្ហាថាតើខ្លួនគួរតែពិចារណាអំពីសាលដីកា ដែលខ្លួនបានសម្រេចលើបណ្តឹងឧទ្ធរណ៍ អបជ ៤៧ និង អបជ ៥៣ ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗដូចខាងក្រោម ដែរឬទេ:

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាខ្មែរក្រោម ចំនួន ១១នាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណដូចខាងក្រោម: 09-VU-02138 (D230/2/15 **អតីត** D22/260); 09-VU-02151 (D230/2/22 **អតីត** D22/273); 09-VU-02150 (D230/2/21/1 **អតីត** D22/272); 09-VU-02148 (D230/2/20 **អតីត** D22/270); 09-VU-02147 (D230/2/19 **អតីត** D22/269); 09-VU-02146 (D230/2/18 **អតីត** D22/0268); 09-VU-02144 (D230/2/17 **អតីត** D22/266); 09-VU-02143 (D230/2/16 **អតីត** D22/265); 09-VU-00638 (D230/2/9 **អតីត** D22/134); 09-VU-02267 (D230/2/10 **អតីត** D22/135); 09-VU-04265 (D230/2/23 **អតីត** D22/274)។

និង

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-00882 (D230/2/6 អតីត D22/288)

២. នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានណែនាំដល់គ្រប់ភាគីទាំងអស់ថា "ភាគីណាមួយដែលមានបំណងដាក់សារណាទាក់ទិននឹងបញ្ហានេះ អាចដាក់ នៅត្រឹមថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ វេលាម៉ោង ៣ រសៀល ជាកំណត់"[៤]។

៣. នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ មេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធទាំងឡាយ បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ[៥]។ ចម្លើយតបទាំងនេះត្រូវបានជូនដំណឹងជាបន្ទាន់ទៅភាគីផ្សេងៗទៀតដោយមានការណែនាំឱ្យភាគីដាក់ចម្លើយតប ប្រសិនបើភាគីមានបំណងដាក់ ដោយមិនឱ្យលើសពីរយៈពេល ២ ថ្ងៃបន្ទាប់ពីថ្ងៃជូនដំណឹងនេះ។

---

[៤] សេចក្តីណែនាំស្តីពីការពិចារណាឡើងវិញលើភាពអាចទទួលយកបាននៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D364/1/4, D274/4/6 និង D250/3/2/1/6។

[៥] ចម្លើយតបទៅនឹងការណែនាំរបស់ អង្គបុរេជំនុំជម្រះស្តីពីការពិចារណាឡើងវិញនូវភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាខ្មែរកម្ពុជាក្រោម ឯកសារ D250/3/2/1/7 ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ("សំណើសុំ របស់អ្នកដាក់ពាក្យសុំជាខ្មែរកម្ពុជាក្រោម")។ និង Demande de reconsideration de la recevabilite de la demande de constitution de partie civile 09-VU-00882 (D230/2/6 autrefois D22/288), D364/1/5, 27 juin 2011 ("D22/288's Request")។

៤. រហូតដល់ពេលនេះ អង្គបុរេជំនុំជម្រះពុំទាន់បានទទួលចម្លើយតបណាមួយនៅឡើយទេ។

៥. នៅក្នុងចម្លើយតបទៅនឹងសេចក្តីណែនាំ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាសារជាថ្មីឡើងវិញអំពីសាលដីកាទាំងឡាយកាលពីមុនរបស់អង្គបុរេជំនុំជម្រះ ដើម្បីទទួលយក និងផ្តល់ដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះនូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២។

**លក្ខណៈវិនិច្ឆ័យរបស់ អ.ប.ជ សម្រាប់ការពិចារណាសារជាថ្មីឡើងវិញ:**

៦. នៅក្នុងច្បាប់យុត្តិសាស្ត្រកាលពីមុន អ.ប.ជ បានអនុវត្តលក្ខណៈវិនិច្ឆ័យខាងក្រោមសម្រាប់ការពិចារណាសារជាថ្មីឡើងវិញ:

> "២៥. សំណើសុំពិចារណាសារជាថ្មីឡើងវិញអាចជោគជ័យបាន តែក្នុងករណីមានមូលដ្ឋានធម្មានុរូបសម្រាប់អង្គបុរេជំនុំជម្រះ ធ្វើការពិចារណាសារជាថ្មីឡើងវិញអំពីសេចក្តីសម្រេចនានាកាលពីមុនរបស់ខ្លួនប៉ុណ្ណោះ[៦]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានលើកឡើងថា អង្គជំនុំជម្រះ "តែងតែអាចធ្វើការពិចារណាសារជាថ្មីឡើងវិញអំពីសេចក្តីសម្រេចដែលខ្លួនបានធ្វើកាលពីមុន មិនត្រឹមតែដោយសារ<u>កាលៈទេសៈប្រែប្រួល</u>ប៉ុណ្ណោះទេ តែថែមទាំងនៅពេលដែលអង្គជំនុំជម្រះបានដឹងថា <u>សេចក្តីសម្រេចកាលពីមុនធ្វើឡើងដោយភ័ន្តច្រឡំ</u> ឬថា សេចក្តីសម្រេចនោះ<u>បានបណ្តាលឱ្យមានភាពអយុត្តិធម៌</u>" [៧]។ ចំណុចនេះត្រូវបានពណ៌នាថាជាអំណាចដែលមានជាប់ជាមួយជាមូលដ្ឋាន[៨] និងជាពិសេសមានសារៈសំខាន់សម្រាប់អង្គភាពមួយរបស់តុលាការដែលជាអ្នកសម្រេចក្រោយបំផុតដូចជាអង្គបុរេជំនុំជម្រះជាដើម។ ការប្រែប្រួលកាលៈទេសៈអាចរួមទាំង

---

[៦] រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milosevic, IT-02-54-T "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឱ្យពិចារណាសារជាថ្មីឡើងវិញពាក់ព័ន្ធនឹងសាក្សីរបស់មេធាវីការពារក្តី Mitar Balevic, Vladislav Jovanovic, Vukasin Andric និង Dobre Aleksovski" ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៦។

[៧] រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milosevic, IT-98-29-AR73 "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍" ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០១ កថាខណ្ឌ ១៣ និងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mucic et al, IT-96-21-Abis " សាលក្រមស្តីពីបណ្តឹងឧទ្ធរណ៍អំពីការ ផ្តន្ទាទោស" ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៣ កថាខណ្ឌ ៤៩។ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង

[៨] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Galic, IT-98-29-A "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំឱ្យពិចារណាសារជាថ្មីឡើងវិញ" ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៦ ទំព័រ ២។

កត្តាថ្មីៗ ឬទឡ្ហីករណ៍ថ្មីៗ[៩]។ បទដ្ឋានសម្រាប់ការពិចារណាជាថ្មីឡើងវិញក៏ត្រូវបានពណ៌នាផង ដែរដូច ខាងក្រោមៈ "អង្គជំនុំជម្រះមាន<u>អំណាចឆន្ទានុសិទ្ធ</u>ជាប់ជាមួយជាមូលដ្ឋាន ដើម្បីធ្វើការពិចារណាសារជាថ្មីឡើងវិញ អំពីសេចក្ដីសម្រេចបន្ទាន់បង្គំកាលពីមុននៅក្នុងករណីលើកលែង "ប្រសិនបើ មានការបង្ហាញថាមាន <u>ការភ័ន្តច្រឡំច្បាស់លាស់</u>ក្នុងការសំអាងហេតុ ឬប្រសិនបើចាំបាច់ធ្វើ ដូច្នេះដើម្បីការពារមិនឲ្យមានភាពអយុត្តិធម៌"[១០]"[១១]។

**អំណះអំណាងរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីគាំទ្រសំណើរបស់ខ្លួនសុំឲ្យពិចារណាសារជាថ្មីឡើងវិញ៖**

៧. ដោយបានប្រើប្រាស់ និងដាក់បញ្ចូល "ទឡ្ហីករណ៍ដែលបានធ្វើឡើងនៅក្នុងសេចក្ដីសម្រេចលើឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ(៤៧)" មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាខ្មែរក្រោម ស្នើសុំ "ឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាខ្មែរក្រោម បានចូលរួមជាដើមបណ្ដឹងពេញលេញដើម្បីទទួល បានយុត្តិធម៌ និងស្មើភាពគ្នា"[១២]។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា "ដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការទទួលយក"[១៣] បានបដិសេធអ្នកដាក់ពាក្យសុំជាខ្មែរក្រោម ដោយភ័ន្តច្រឡំ ដោយផ្អែកលើមូលដ្ឋានថា "ទំនាក់ទំនងរវាងហេតុ និងផល ដែលចាំបាច់រវាងព្យសនកម្ម និងអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេត មិនកើតមានចំពោះអ្នកដាក់ពាក្យជាខ្មែរក្រោម នោះទេ"[១៤] និងកត់សម្គាល់ឃើញថា កូនក្ដីរបស់ខ្លួននឹងគ្មានឱកាសដើម្បីដេញដោល

---

[៩] រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Galic, IT-98-29-A "សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំឲ្យពិចារណាសារជាថ្មីឡើងវិញ" ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៦ ទំព័រ ២។

[១០] រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Milutinovic et al, IT-05-87-T "សេចក្ដីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំវិធានការការពារពាក់ព័ន្ធនឹងសវនាការបន្ថែមទៀត K56" ចុះថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ២។

[១១] សេចក្ដីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ កថាខណ្ឌ ២៥ (ជើងទំព័រមិនត្រូវបានលុបចោលទេសម្រាប់ជួយសម្រួលការយោង)។

[១២] ពាក្យសុំរបស់អ្នកដាក់ពាក្យសុំជាខ្មែរកម្ពុជាក្រោម កថាខណ្ឌ ៧។

[១៣] ពាក្យសុំរបស់អ្នកដាក់ពាក្យសុំជាខ្មែរកម្ពុជាក្រោម កថាខណ្ឌ ៦ ដែលយោងទៅកថាខណ្ឌ ១៩ នៃសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្ដីពីការទទួលយកឬនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលទាក់ទងនឹងសំណើលេខ [illegible] ចុះថ្ងៃទី១៣ ខែ មករា ឆ្នាំ ២០១០ លេខសំគាល់ ឌ ២៥០/៣/២ ។

[១៤] ពាក្យសុំរបស់អ្នកដាក់ពាក្យសុំជាខ្មែរកម្ពុជាក្រោម កថាខណ្ឌ ៦។

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

បញ្ហានេះថែមទៀតទេ ពីព្រោះអង្គបុរេជំនុំជម្រះគឺជាវិធីតែមួយគត់ដើម្បីដោះស្រាយផលប៉ះពាល់នៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍លើកទីមួយរបស់ខ្លួន[១៥]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ខ្លួនឯកភាពជាមួយនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះនិងលើកឡើងថាពាក្យសុំរបស់ខ្មែរក្រោម ត្រូវធ្វើការពិចារណាសារជាថ្មីឡើងវិញ ដោយប្រើ "លក្ខណៈវិនិច្ឆ័យទទួលស្គាល់ ដើមបណ្តឹងរដ្ឋប្បវេណីទូលំទូលាយជាង" អ្វីដែលមតិភាគច្រើននៃអង្គបុរេជំនុំជម្រះបានពឹងផ្អែកនៅក្នុងសាលដីកា ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១[១៦]។

៨. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខ D22/288 បានស្នើឱ្យអង្គបុរេជំនុំជម្រះពិនិត្យមើលសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០ ដែល ក.ស.ច.ស បានសម្រេចមិនទទួលស្គាល់ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខD22/288 ។ ពួកគេបានជម្រុញឱ្យអង្គបុរេជំនុំជម្រះពិនិត្យឡើងវិញនូវពាក្យសុំ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខD22/288 ដោយផ្អែកមូលដ្ឋានថ្មី ដូចមានគូសបញ្ជាក់ក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១[១៧]។

## ការពិចារណារបស់អង្គបុរេជំនុំជម្រះទៅលើសំណើសុំឱ្យពិចារណាឡើងវិញ៖

៩. ពាក់ព័ន្ធនឹងសំណើរបស់អ្នកដាក់ពាក្យសុំខ្មែរក្រោម បន្ទាប់ពីបានរកឃើញថា សេចក្តីសម្រេចនាពេលកន្លងមកលើពាក្យសុំទាំងអស់នេះ បានអនុវត្តលក្ខណៈវិនិច្ឆ័យផ្លូវច្បាប់ពុំត្រឹមត្រូវក្នុងការសម្រេចមិនទទួលយកពាក្យសុំទាំងអស់នោះ[១៨] មតិភាគច្រើនយល់ឃើញថាមានមូលហេតុគ្រប់គ្រាន់ក្នុងការពិចារណាឡើងវិញ ទៅលើសេចក្តីសម្រេចពីមុនស្តីពីការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ពាក្យសុំទាំងនេះនឹងទទួល បានការពិនិត្យពិចារណាឡើងវិញ ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យក្នុងការទទួលយកពាក្យសុំ ដែលមតិភាគច្រើននៃអង្គបុរេជំនុំជម្រះធ្លាប់បាន

---

[១៥] ពាក្យសុំរបស់អ្នកដាក់ពាក្យសុំជាខ្មែរកម្ពុជាក្រោម កថាខណ្ឌ ៨។

[១៦] ពាក្យសុំរបស់អ្នកដាក់ពាក្យសុំជាខ្មែរកម្ពុជាក្រោម កថាខណ្ឌ ៣ និង៤។

[១៧] សំណើរបស់ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខ D22/288 កថាខណ្ឌ ៦-៨។

[១៨] សាលដីកាលើគ្រប់បណ្តឹងទាំងអស់ ប្រឆាំងនឹងសេចក្តីសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារលេខ D 404/2/4, កថាខណ្ឌ ១០១-១០៥ និង ១១៣។

00711577



អនុវត្តនៅក្នុងសាលដីការបស់ខ្លួន ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀតទាំងអស់។[១៩]

១០. មតិភាគច្រើនកត់សម្គាល់ឃើញថា តាមរយៈការដាក់បញ្ចូលគ្នា សំណើសុំឱ្យពិចារណាឡើងវិញ លើកឡើងអំពីទឡ្ហីករណ៍របស់សហមេធាវីក្នុងការទទួលយកពាក្យសុំ ដែលមាននៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួនដែលបានដាក់ក្នុងឯកសារ អ.ប.ជ ៤៧។ នៅក្នុងបណ្ដឹងឧទ្ធរណ៍នោះ សហមេធាវីបានគូសបញ្ជាក់ថាជារួមថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលត្រូវបានចោទប្រកាន់ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយចំនួនទៀត ដែលត្រូវបានចោទ ប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម គឺជាឧក្រិដ្ឋកម្មផ្អែកលើការធ្វើទុក្ខបុកម្នេញ ដែលយកក្រុមមនុស្សណាមួយធ្វើជាគោលដៅ ហើយ ខ្មែរក្រហមបានយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីខ្មែរក្រោម ធ្វើជាគោលដៅ ដោយសារពួកវាយល់ថាពួកគាត់មានសញ្ជាតិវៀតណាម/ឬជនជាតិភាគតិច[២០]។ សហមេធាវីពុំបានលើកទឡ្ហីករណ៍ណាមួយជាក់លាក់ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំម្នាក់ៗឡើយ ក្រៅពីអ្នកដាក់ពាក្យសុំដែលមានលេខសម្គាល់ 09-VU-02147។ មតិភាគច្រើននៃអង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍ជាទូទៅ ដែលសហមេធាវីបានលើកពាក់ព័ន្ធនឹងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់កូនក្ដីរបស់ខ្លួន គឺពុំទាន់គ្រប់គ្រាន់ដើម្បីសម្រេចលើបញ្ហានេះ ដោយយោងតាមលក្ខខណ្ឌតម្រូវក្នុងការទទួលយកពាក្យសុំ ដែលអង្គបុរេជំនុំជម្រះបានកំណត់នៅ ក្នុងសាលដីកាសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោះទេ។ ការអះអាងរបស់មេធាវី ត្រឹមតែថាកូនក្ដីរបស់ខ្លួនគឺជាជនរងគ្រោះពីការធ្វើទុក្ខបុកម្នេញ ពុំទាន់គ្រប់គ្រាន់ឡើយ ក្នុងការឱ្យអង្គបុរេជំនុំជម្រះទទួលស្គាល់កូនក្ដីរបស់ខ្លួន ដោយពុំចាំបាច់លើកឡើងនូវពាក្យសុំណាមួយជាក់លាក់។ ដូច្នេះ មតិភាគច្រើនយល់ឃើញថាជាការសមស្របដែលត្រូវពិនិត្យ និងវាយតម្លៃឡើងវិញ ទៅលើពាក្យសុំនីមួយៗដើម្បីសម្រេចថាតើអ្នកដាក់ពាក្យសុំ ពិតជាបានទទួលរងព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មដែលបង្កើតបានជាផ្នែកមួយនៃគោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងប្រាំ ដែលខ្មែរក្រហមបានដាក់អនុវត្តដែរ ឬទេ ដូចដែលខ្លួនធ្លាប់

---

[១៩] សាលដីកាលើគ្រប់បណ្ដឹងទាំងអស់ ប្រឆាំងនឹងសេចក្ដីសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារលេខ D404/2/4 និង D4[illegible]/3/6។

[២០] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើ D250/3, ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០, ឯកសារ D250/3/2/1/1 ត្រង់កថាខណ្ឌ ១(ខ)(ii)-(iv)។

បានសម្រេចកន្លងមកនៅក្នុងសាលដីកា របស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី។

១១. ពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ D22/288 ដែលត្រូវបានដោះស្រាយនៅក្នុងសាលដីកាមុនរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ អ.ប.ជ ៥៣[២១] មតិភាគច្រើនកត់សម្គាល់ឃើញថានៅក្នុងសាលដីកានោះ ខ្លួនពុំមានមតិគាំទ្រភាគច្រើនឡើយ ព្រោះយ៉ាងហោចណាស់ត្រូវការការឯកភាពពីសំណាក់ចៅក្រម៤រូបដើម្បីអាចសម្រេចលើបញ្ហាទាំងប៉ុន្មានដែលបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍នោះ។ ដូច្នេះដីការបស់សហចៅក្រមស៊ើបអង្កេត ដែលបានប្រកាសពុំទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ D22/288 គឺជាដីកាសម្រេចស្ថាពរ។ តាមសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យសុំរូបនេះ អ្នកដាក់ពាក្យសុំ ពុំបានផ្ដល់ភស្តុតាងបញ្ជាក់អំពីទំនាក់ទំនងផ្ទាល់រវាងព្យសនកម្មដែលបានចោទប្រកាន់ និង *អង្គហេតុក្រោមកិច្ចស៊ើបសួរ*[២២] ឡើយ។ មតិភាគច្រើនយល់ឃើញថាការភ័ន្តច្រឡំជាក់ស្ដែងក្នុងការផ្ដល់សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងការសម្រេចបដិសេធនេះតម្រូវឲ្យចាំបាច់ត្រូវពិនិត្យពិចារណាឡើងវិញ ចំពោះពាក្យសុំរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ D22/288 ដោយផ្អែកលើការយល់ឃើញទូទៅរបស់មតិភាគច្រើននៃអង្គបុរេជំនុំជម្រះ នៅក្នុងសាលដីការបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ។

### ការវាយតម្លៃលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ

១២. មតិភាគច្រើនពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ មតិភាគច្រើនយល់ឃើញថា អ្នកដាក់ពាក្យសុំទំនងជាអាចបានទទួលរងព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដើម្បីសម្រេចគោលនយោបាយមួយ ក្នុងចំណោមគោលនយោបាយទាំងប្រាំ ដែលគេបានចោទថាខ្មែរក្រហមជាអ្នកបានដាក់ឲ្យអនុវត្ត ដូចមានបញ្ជាក់លម្អិតដូចខាងក្រោម៖

---

[២១] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចមិនទទួលយកសំណើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី D22/288, ឯកសារលេខ D364/1/3, ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១០។

[២២] ដីកាសម្រេចមិនទទួលយកសំណើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី D22/288, ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ , ឯកសារ D364។

00711579



| អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែល ស.ច.ស បានបដិសេធ | សំអាងហេតុក្នុងការទទួលយកពាក្យសុំ | ជនរងគ្រោះផ្ទាល់ |
|---|---|---|
| 09-VU-02138 (D22/260) (D230/2/15) | ការដាក់ជាទាសករនៅខេត្តតាកែវ | អ្នកដាក់ពាក្យសុំ |
| 09-VU-02151 (D22/273) (D230/2/22) | ការដាក់ជាទាសករនៅភូមិជំនិត ដែលនាពេលបច្ចុប្បន្ន ភូមិនេះអាចស្ថិតនៅក្នុង ខេត្តបន្ទាយមានជ័យ | អ្នកដាក់ពាក្យសុំ និងក្រុមគ្រួសារ |
| 09-VU-02150 (D22/272) (D230/2/21/1) | ការដាក់ជាទាសករនៅឃុំ Ta Lou ខេត្តពោធិសាត់ | អ្នកដាក់ពាក្យសុំ |
| 09-VU-02148 (D22/270) (D230/2/20) | ការដាក់ជាទាសករនៅស្រុកបាកាន ខេត្តពោធិសាត់ | អ្នកដាក់ពាក្យសុំ និងក្រុមគ្រួសារ |
| 09-VU-02147 (D22/269) (D230/2/19) | ការដាក់ជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការវាយប្រហារលើសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ នៅស្រុកបាកាន ខេត្តពោធិសាត់ | អ្នកដាក់ពាក្យសុំ |
| 09-VU-02146 (D22/0268) (D230/2/18) | ការដាក់ជាទាសករនៅស្រុកបាកាន ខេត្តពោធិសាត់ | អ្នកដាក់ពាក្យសុំ និងក្រុមគ្រួសារ |
| 09-VU-02144 (D22/266) (D230/2/17) | ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា មកលើពុទ្ធសាសនិក | បងប្អូនប្រុសរបស់អ្នកដាក់ពាក្យសុំ ជាព្រះសង្ឃមួយអង្គដែលខ្មែរក្រហមចាប់ផ្សឹក |
| 09-VU-02143 (D22/265) (D230/2/16) | ការដាក់ជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការវាយប្រហារមកលើសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិនៅស្រុកបាកាន ខេត្ត | អ្នកដាក់ពាក្យសុំ |

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

| | | |
|---|---|---|
| | ពោធិសាត់ | |
| 09-VU-00638 (D22/134) (D230/2/9) | ការដាក់ជាទាសករនៅស្រុកបាកាន ខេត្តពោធិសាត់ | អ្នកដាក់ពាក្យសុំ និងក្រុមគ្រួសារ |
| 09-VU-02267 (D22/135) (D230/2/10) | ការធ្វើទារុណកម្ម, ការដាក់ជាទាសករ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅគុក Peam Nil ខេត្តបាត់ដំបង | អ្នកដាក់ពាក្យសុំ ជាទាហានជាប់ចោទពីបទជាប់ខ្សែរយៈនឹងរបប លន់ នល់ |
| 09-VU-04265 (D22/274) (D230/2/23) | ការដាក់ជាទាសករនៅស្រុកមោងឫស្សី ខេត្តបាត់ដំបង | ឪពុកម្ដាយរបស់អ្នកដាក់ពាក្យសុំ |

១៣. តាមសំអាងហេតុទូទៅនានា ដែលមាននៅក្នុងសេចក្ដីសម្រេចរបស់មតិភាគច្រើននៃអង្គបុរេជំនុំជម្រះនៅក្នុងសាលដីការបស់ខ្លួនដែលបានជូនដំណឹងកាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ មតិភាគច្រើននៃអង្គបុរេជំនុំជម្រះយល់ឃើញថា អង្គបុរេជំនុំជម្រះត្រូវទទួលស្គាល់អ្នកដាក់ពាក្យសុំក្នុងឯកសារ អ.ប.ជ ៥៣ ដោយហេតុថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ (ដែលមានលេខសម្គាល់ D230/2/6 អតីត D22/288) អាចទំនងជាជនរងគ្រោះដោយសារការអនុវត្តគោលនយោបាយ "ការអប់រំ "សមាសភាពមិនល្អ" និង ការសម្លាប់ "ខ្មាំង" ទាំងក្នុង និងក្រៅជួរបក្ស"[២៣]។ ដូច្នេះ មតិភាគច្រើនសូមទទួលស្គាល់អ្នកដាក់ពាក្យសុំរូបនេះជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេច៖**

១. ទទួលស្គាល់ និងផ្ដល់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២ តាមមតិភាគច្រើន មតិជំទាស់ពីចៅក្រម **Marchi- Uhel** ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ដែលមានលេខសម្គាល់ដូចតទៅ៖ 09-VU-02138 (D230/2/15 **អតីត** D22/260); 09-VU-02151 (D230/2/22 **អតីត** D22/273); 09-VU-02150 (D230/2/21/1 **អតីត** D22/272); 09-VU-02148 (D230/2/20 **អតីត** D22/270); 09-VU-02147 (D230/2/19 **អតីត** D22/269); 09-VU-02146

[២៣] សូមមើលកថាខណ្ឌ ១៥៧ នៃដីកាដំណោះស្រាយ។



PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * C.C.C. * C.E.T.C. *

(D230/2/18 អតីត D22/0268); 09-VU-02144 (D230/2/17 អតីត D22/266); 09-VU-02143 (D230/2/16 អតីត D22/265); 09-VU-00638 (D230/2/9 អតីត D22/134); 09-VU-02267 (D230/2/10 អតីត D22/135); 09-VU-04265 (D230/2/23 អតីត D22/274)។

២. ទទួលស្គាល់ និងផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២ តាមមតិភាគច្រើន មតិជំទាស់ពីចៅក្រម **Marchi- Uhel** ចំពោះអ្នកដាក់ពាក្យសុំដែលមានលេខសម្គាល់ 09-VU-00882 (ដែលមានលេខសម្គាល់ D230/2/6 អតីត D22/288)។

ភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **នំយ ធូល** **Catherine MARCHI-UHEL** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

ចៅក្រម Catherine Marchi Uhel បានដាក់ភ្ជាប់មកជាមួយនូវគំនិតជំទាស់មួយចំនួនរបស់ខ្លួន។

**គំនិតជំទាស់ដោយឡែករបស់ចៅក្រម Catherine Marchi Uhel**

១. ខ្ញុំបានអានរួចហើយនូវគំនិតរបស់ចៅក្រមភាគច្រើន (មតិភាគច្រើន) ដែលមាននៅក្នុងសាលដីកាស្ដីពីការពិចារណាឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំយល់ឃើញថា សេចក្ដីសម្រេចតាមមតិភាគច្រើន ក្នុងការពិចារណាឡើងវិញនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលកន្លងមក សាលដីកា អ.ប.ជ ៤៧ និង អ.ប.ជ ៥៣ ធ្លាប់បានបដិសេធមិនទទួលស្គាល់ គឺស្របតាមវិធីសាស្ត្រថ្មី ដែលខ្លួនបានអនុវត្តនៅក្នុងសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ("សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី")។ មតិភាគច្រើននៃអង្គបុរេជំនុំជម្រះ៖ ១) បានសន្និដ្ឋានថាការភ័ន្តច្រឡំមួយចំនួនរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការគ្រប់គ្រងប្រព័ន្ធផែនការទទួលយកអ្នកដាក់ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវពិនិត្យឡើងវិញនូវពាក្យសុំរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍[24] ២)បានយល់ឃើញថាអ្នកដាក់ពាក្យសុំទាំងនោះ មានភស្ដុតាងគ្រប់គ្រាន់ក្នុងការបញ្ជាក់ថាខ្លួនបានទទួលរងព្យសនកម្ម ដោយសារគោលនយោបាយមួយនៅក្នុងចំណោមគោលនយោបាយទាំងប្រាំ ដែលបង្កើតបានជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអាចទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២[២៥]។

២. ប៉ុន្តែ តាមសំអាងហេតុដែលមានបញ្ជាក់នៅក្នុងគំនិតជំទាស់មួយផ្នែកដោយឡែករបស់ខ្ញុំ លើសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមជំទាស់នឹងមតិភាគច្រើននៃអង្គបុរេជំនុំជម្រះ ដែលថាសាលដីកាមុនៗរបស់អង្គបុរេជំនុំជម្រះមានអានុភាព ក្នុងការមិនទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្អែកទៅលើមូលហេតុដែលពុំត្រឹមត្រូវ ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីកំពុងស្នើសុំឲ្យមានការពិចារណាជាថ្មីឡើងវិញ [២៦]។ ការយល់ឃើញដោយឡែក

---

[២៤] ក្នុងចំណោមចំណុចផ្សេងៗ សូមមើល កថាខណ្ឌ ៥៥ នៃសាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេតស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ D404/2/4 ("សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី")។

[២៥] ក្នុងចំណោមចំណុចផ្សេងៗ សូមមើល កថាខណ្ឌ ៧៧ នៃសាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី។

[២៦] ខ្ញុំក៏មិនឯកភាពដែរ ទៅនឹងការលើកឡើងនៅក្នុងសេចក្ដីណែនាំអំពីការពិចារណាឡើងវិញទៅលើលទ្ធភាពទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ D250/3/1/6, កថាខណ្ឌ ១។

របស់ខ្ញុំទៅលើចំណុចទាំងពីរខាងលើ ធ្វើឱ្យខ្ញុំសន្និដ្ឋានថាជាការពុំត្រឹមត្រូវទេដែលអង្គបុរេជំនុំជម្រះត្រូវពិចារណាឡើងវិញទៅលើពាក្យសុំទាំងអស់នេះ ដែលសាលដីកា អ.ប.ជ ៤៧ និង អ.ប.ជ ៥៣ ធ្លាប់បានបដិសេធមិនទទួលស្គាល់ម្តងរួចមកហើយ[២៧]។ សំណើរបស់សហមេធាវីដែលបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាឡើងវិញ គឺផ្អែកទៅលើទឡ្ហីករណ៍តែមួយដូចដែលខ្លួនធ្លាប់បានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួននៅក្នុងសំណុំរឿង អ.ប.ជ ៤៧ និង អ.ប.ជ ៥៣ ។ ទឡ្ហីករណ៍ទាំងនេះត្រូវបានដាក់បញ្ចូលជាឯកសារយោងនៅក្នុងសំណើនាពេលបច្ចុប្បន្ន ដែលបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាឡើងវិញ។ ដោយសារខ្ញុំនៅរក្សាគោលជំហរដដែល ពាក់ព័ន្ធនឹងទំនាក់ទំនងចាំបាច់រវាងព្យសនកម្មដែលអាចមាន និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់មកលើជនជាប់ចោទ ខ្ញុំយល់ថាពុំមានមូលដ្ឋានណាមួយសម្រាប់ឱ្យ អង្គបុរេជំនុំជម្រះត្រូវធ្វើការពិចារណាឡើងវិញនោះទេ ។ ត្រង់ចំណុចដែលពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំនៅក្នុងឯកសារ អ.ប.ជ ៥៣ ខ្ញុំសូមបញ្ជាក់ថាបន្ថែមពីលើគំនិតដែលបានបញ្ជាក់នៅក្នុងសាលដីកា អ.ប.ជ ៥៣ នៅក្នុងគំនិតជំទាស់របស់ខ្ញុំ ខ្ញុំបានពន្យល់បន្ថែមរួចហើយអំពីមូលហេតុដែលខ្ញុំពុំព្រមទទួលស្គាល់អ្នកដាក់ពាក្យសុំរូបនោះ ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំ-រឿង ០០២[២៨]។

ភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

ចៅក្រមអន្តរជាតិ Catherine Marchi-Uhel

---

២៧ តាមហេតុផលដដែល ខ្ញុំបានបដិសេធពុំព្រមពិចារណាឡើងវិញទៅលើពាក្យសុំរបស់ជនជាតិវៀតណាម ដែលបានដាក់ក្នុងលក្ខណៈជាសំណើសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាឡើងវិញ នៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង (ឯកសារ D417), ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D417/2/3 (“បណ្តឹងឧទ្ធរណ៍, អ.ប.ជ ៧៤)៖ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី, ឧបសម្ពន្ធពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលចៅក្រម Marchi-Uhel ទទួលស្គាល់, កថាខណ្ឌ ១៥៥។

២៨ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី, គំនិតជំទាស់មួយផ្នែកដោយឡែកទៅនឹងសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៣៥-៣៦។